ASEAN PARLIAMENTARIANS FOR HUMAN RIGHTS

# សមាជិកសភានៃតំបន់អាស៊ីអាគ្នេយ៍ សម្តែងនូវការព្រួយបារម្ភយ៉ាងខ្លាំងចំពោះសិទ្ធិអំណាចក្នុងភាពអាសន្នដ៏ធំទូលំទូលាយហួសប្រមាណ នៅក្នុងប្រទេសម៉ាឡេស៊ី

យើងខ្ញុំ ជាសមាជិកសភាដែលមានរាយនាមដូចខាងក្រោម មានការព្រួយបារម្ភយ៉ាងខ្លាំងថា សិទ្ធិអំណាចដែលមានផលប៉ះពាល់យ៉ាងទូលំទូលាយរបស់អាជ្ញាធរម៉ាឡេស៊ី ស្ថិតក្រោមភាពអាសន្ននាពេលបច្ចុប្បន្ន មិនត្រឹមតែបង្កឲ្យមានហានិភ័យនៃការបំផ្លាញមូលដ្ឋានគ្រឹះនៃលទ្ធិប្រជាធិបតេយ្យរបស់ប្រទេសម៉ាឡេស៊ីប៉ុណ្ណោះទេ ប៉ុន្តែក៏បើកឱកាសយ៉ាងធំទូលាយឲ្យមានការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរផងដែរ។ ហេតុនេះ យើងខ្ញុំ សូមអំពាវនាវឲ្យមានការអនុញ្ញាតឲ្យសភាបន្តបំពេញមុខការរបស់ខ្លួនដោយគ្មានការរឹតត្បិត។

កាលពីដើមឆ្នាំនេះ ព្រះមហាក្សត្រម៉ាឡេស៊ីបានប្រកាសភាពអាសន្ន ដែលមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃទី១១ ខែមករា រហូតដល់ថ្ងៃទី០១ ខែសីហា ដោយលើកហេតុផលសំអាងថា វីរុសក្សរ៉ូណា បង្កការគម្រាមកំហែងដល់សន្តិសុខ សេដ្ឋកិច្ច និងសណ្តាប់ធ្នាប់សាធារណៈរបស់ប្រទេស។ បន្ទាប់ពីការប្រកាសនេះ ក៏មានការដាក់ចេញនូវបទបញ្ជាភាពអាសន្ន (អំណាចចាំបាច់) ឆ្នាំ២០២១ ដែលប្រគល់សិទ្ធិអំណាចយ៉ាងធំទូលំទូលាយហួសប្រមាណឲ្យអាជ្ញាធរម៉ាឡេស៊ី ខណៈពេលដែលអាជ្ញាធរកំពុងបិទបាំង និងការពារសកម្មភាពរបស់ខ្លួនពីការត្រួតពិនិត្យដោយតុលាការ ឬដោយសភា។

ជាពិសេស បទបញ្ជានេះបានដកចេញនូវការត្រួតពិនិត្យដោយសភា និងបានកម្រិតអំណាចតុលាការលើមន្ត្រីរដ្ឋការក្នុងអំឡុងពេលនៃភាពអាសន្ននេះ។ ផ្នែកទី១០ បានការពាររដ្ឋាភិបាល និងភ្នាក់ងាររដ្ឋាភិបាល ដែលត្រូវបានចាត់តាំងដើម្បីចេញសេចក្តីណែនាំតាមនីតិវិធីច្បាប់ ក្រោមច្បាប់ស្តីពីការទប់ស្កាត់ និងគ្រប់គ្រងជំងឺឆ្លង ឆ្នាំ១៩៨៨ ពាក់ព័ន្ធនឹង “រាល់អំពើការធ្វេសប្រហែស ឬការខកខានមិនបានបំពេញកាតព្វកិច្ច ដែលត្រូវបានប្រព្រឹត្ត ឬមិនត្រូវបានប្រព្រឹត្ត....ដោយសេចក្តីស្មោះត្រង់” ខណៈដែលផ្នែកទី១៤ និងទី១៥ បានព្យួរការប្រជុំសភា និងរដ្ឋសភា រហូតដល់មានការកំណត់ពេលវេលាដោយព្រះមហាក្សត្រ។ ផ្នែកទី១២ (៦) នៃបទបញ្ជានេះក៏បញ្ជាក់ផងដែរថា ការបោះឆ្នោតសកលនឹងត្រូវបានរៀបចំ នៅពេលវេលាដែលព្រះមហាក្សត្រព្រះរាជតម្រិះថា “មានភាពសមស្រប” តែប៉ុណ្ណោះ។

លើសពីនេះទៅទៀត ផ្នែកទី៧ នៃបទបញ្ជានេះ ផ្តល់នូវសិទ្ធិអំណាចបន្ថែមទៀតដល់កងកម្លាំងប្រដាប់អាវុធ

ដែលរួមមានទាំងសិទ្ធិអំណាចក្នុងការឃុំខ្លួនអ្នកដែលរំលោភបំពានបទបញ្ជាគ្រប់គ្រងសកម្មភាព និងចាប់ខ្លួនជនចំណាកស្រុក ដែលត្រូវបានរកឃើញថាបានចូលប្រទេសម៉ាឡេស៊ីដោយខុសច្បាប់ នេះបើយោងតាមរដ្ឋមន្ត្រីក្រសួងការពារជាតិម៉ាឡេស៊ី។

យើងខ្ញុំសូមដាស់តឿនអាជ្ញាធរថា ដើម្បីធានាថា វិធានការក្នុងភាពអាសន្នមិនត្រូវបានប្រើប្រាស់ដើម្បីបង្ក្រាបសិទ្ធិមនុស្ស ឬក្តោបក្តាប់ស្ថាប័នប្រជាធិបតេយ្យជាអចិន្ត្រៃយ៍ដោយខុសច្បាប់នោះទេ វិធានការទាំងនោះគួរតែមានលក្ខណៈចាំបាច់ និងសមស្រប ក្នុងការដោះស្រាយបញ្ហានៃការគម្រាមកំហែងដែលចាំបាច់ត្រូវកាត់បន្ថយ ក្នុងកាលៈទេសៈដែលត្រូវទប់ស្កាត់ការរីករាលដាលនៃជំងឺ COVID-19 នេះ។ សិទ្ធិអំណាចបែបនេះគួរតែមានលក្ខណៈបណ្តោះអាសន្ន ដែលអាចត្រូវបានត្រួតពិនិត្យដោយតុលាការ ឬដោយសភា ហើយមិនគួរត្រូវបានប្រើប្រាស់ដោយរើសអើង ដើម្បីសំដៅទៅក្រុមជាក់លាក់ណាមួយឡើយ។

សិទ្ធិអំណាចក្នុងភាពអាសន្នរបស់ប្រទេសម៉ាឡេស៊ីត្រូវបានមើលឃើញយ៉ាងច្បាស់ថា មិនសមស្របជាមួយនឹងបទដ្ឋានអន្តរជាតិដែលត្រូវបានបង្កើតឲ្យមាននោះឡើយ និងបង្កើតឲ្យមាននូវបរិយាកាសមួយដែលការទទួលខុសត្រូវរបស់រដ្ឋាភិបាលមានកម្រិតតិចតួចបំផុត ហើយដែលអាចបណ្តាលឲ្យកើតមាននូវការរំលោភអំណាច។

ក្នុងនាមជាអង្គតំណាងឲ្យឆន្ទៈប្រជាពលរដ្ឋ សភាដើរតួនាទីស្នូលនៅក្នុងដំណើរការនៃលទ្ធិប្រជាធិបតេយ្យ ហើយការព្យួរសភានាពេលបច្ចុប្បន្ននេះបានដកហូតសិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការចូលរួមក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្ត។ វាជាការគួរឲ្យព្រួយបារម្ភណាស់ ជាពិសេសនៅពេលដែលការសម្រេចចិត្តរបស់រដ្ឋាភិបាលបង្កឲ្យមានផលវិបាកយូរអង្វែងដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។

ដោយមើលឃើញពីការណ៍ដែលវិធានការក្នុងភាពអាសន្ននៅក្នុងតំបន់ រួមមានវិធានការនៅក្នុងប្រទេសថៃ និងក្នុងប្រទេសហ្វីលីពីនផងដែរ បាននាំឲ្យមានការរឹតត្បិតដល់សេរីភាពជាមូលដ្ឋាន វាពិតជាមានសារៈសំខាន់ជាងពេលណាៗទាំងអស់សម្រាប់សភាក្នុងការបំពេញមុខការរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព និងការពារមិនឲ្យមានការរំលោភអំណាចណាមួយ។

ហេតុដូចនេះ ក្នុងនាមជាសមាជិកសភាជាប់ឆ្នោតតាមបែបបទប្រជាធិបតេយ្យមកពីតំបន់អាស៊ីអាគ្នេយ៍ យើងខ្ញុំសូមស្នើព្រះមហាក្សត្រ ប្រធានសភាតំណាងរាស្ត្រ និងនាយករដ្ឋមន្ត្រីម៉ាឡេស៊ី ធ្វើការកោះប្រជុំសភាក្នុងពេលវេលាកាន់តែឆាប់តាមដែលអាចធ្វើទៅបាន ដើម្បីធានាឲ្យមានការទទួលខុសត្រូវរបស់រដ្ឋាភិបាល ដើម្បីត្រួតពិនិត្យឡើងវិញនូវវិធានការក្នុងភាពអាសន្ន ដើម្បីការពារសិទ្ធិមនុស្ស

និងដើម្បីចូលរួមក្នុងការធ្វើសេចក្តីសម្រេចលើគោលនយោបាយសំខាន់ៗ។ យើងខ្ញុំក៏សូមអំពាវនាវដល់ប្រធានសភាតំណាងរាស្ត្រ ធានាថា គណៈកម្មការសភានៅតែមានដំណើរការយ៉ាងសកម្ម និងបន្តបើកកិច្ចប្រជុំជាទៀងទាត់។ សភានៅទូទាំងពិភពលោកបានបង្កើតឲ្យមាននូវវិធីសាស្ត្រច្នៃប្រឌិតថ្មី និងបែបបទការពារថ្មីតាមប្រព័ន្ធអ៊ីនធឺណេត ដើម្បីធានាថា សភានៅតែអាចបន្តបំពេញការងារចាំបាច់របស់ខ្លួនក្នុងអំឡុងពេលនៃការរីករាលដាលនៃជំងឺឆ្លងនេះ ហើយដែលវិធីសាស្ត្រ និងបែបបទការងារបែបនេះក៏អាចយកមកប្រើការបានដោយប្រទេសម៉ាឡេស៊ី។